ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# សេចក្តីប្រកាសព័ត៌មាន

ក្នុងរយៈពេលថ្មីៗកន្លងមកនេះ សារព័ត៌មានក្នុងស្រុកមួយបានចុះផ្សាយនូវអត្ថបទព័ត៌មានបំផ្លើសខុសពីការពិត និងគ្មានមូលដ្ឋានច្បាស់លាស់ត្រឹមត្រូវ ដោយចោទប្រកាន់ក្នុងចេតនាធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជុំវិញការចុះហត្ថលេខាលើសញ្ញាបត្ររបស់និស្សិតនៃសាកលវិទ្យាល័យកម្ពុជា ។

ចំពោះការផ្សាយព័ត៌មានខាងលើនេះ ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដល់សាធារណជនមេត្តាជ្រាបថា តំណែងជាប្រធាន Board of Trustees នៃសាកលវិទ្យាល័យកម្ពុជា គឺជាតំណែងកិត្តិយសសុទ្ធសាធ ហើយកន្លងមក ក្នុងមុខតំណែងកិត្តិយសនេះ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចតែមួយគត់គឺចុះហត្ថលេខាលើសញ្ញាបត្ររបស់និស្សិត ដែលបានបញ្ចប់ការសិក្សាដោយជោគជ័យនៅសាកលវិទ្យាល័យកម្ពុជា ដោយមិនមានភារកិច្ច និងការទទួលខុសត្រូវផ្សេងទៀតណាមួយដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងប្រតិបត្តិការប្រចាំថ្ងៃរបស់សាកលវិទ្យាល័យកម្ពុជាឡើយ ហើយម្យ៉ាងទៀត ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនដែលបានទទួលផលប្រយោជន៍ពីកិច្ចការអាជីវកម្មរបស់សាកលវិទ្យាល័យកម្ពុជាដែរ ។ ទន្ទឹមនេះ ដើម្បីចៀសវាងការភ័ន្តច្រឡំជាយថាហេតុពីសាធារណជនទូទៅ ដោយសារការផ្សាយព័ត៌មានបំភ្លើសការពិត និងដោយមានការមមាញឹកជាមួយនឹងភារកិច្ចចាំបាច់ច្រើន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានលាលែងចេញពីតំណែងកិត្តិយសជាប្រធាន Board of Trustees នៃសាកលវិទ្យាល័យកម្ពុជារួចហើយដែរ ។

អាស្រ័យហេតុនេះ ខុទ្ទកាល័យសូមធ្វើការបដិសេធទាំងស្រុងចំពោះរាល់សារព័ត៌មានណាដែលបាន និងកំពុងបន្តចុះផ្សាយអត្ថបទព័ត៌មានដែលចោទប្រកាន់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទាក់ទិននឹងប្រធានបទខាងលើ និងអំពាវនាវដល់សារព័ត៌មានពាក់ព័ន្ធ សូមប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មានក្នុងការផ្សព្វផ្សាយព័ត៌មានដែលមានប្រភពពិតប្រាកដ ត្រឹមត្រូវ ប្រកបដោយសុចរិតភាព ដើម្បីរួមចំណែកលើកស្ទួយវិស័យសារព័ត៌មាននៅក្នុងប្រទេសកម្ពុជា ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥*

**ខុទ្ទកាល័យ**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798